# របាយការណ៍ផ្នែកកសិកម្មសម្រាប់ឆ្នាំ២០១៧-២០១៨

## ACIAR Project ASEM/2013/003



## សេចក្តីណែនាំ

គម្រោងកសិកម្មអំពីការដាក់បញ្ចូលបច្ចេកវិទ្យាកសិកម្មរបស់កសិករ (ASEM/2013/003) របស់មជ្ឈមណ្ឌលអូស្ត្រាលីដើម្បីការស្រាវជ្រាវកសិកម្មអន្តរជាតិដែលដំណើរការចាប់ពីខែ មេសា ឆ្នាំ២០១៧ដល់ខែធ្នូឆ្នាំ២០២០ ក្នុងគោលបំណងដើម្បីបង្កើនការរកប្រាក់ចំណូលរបស់កសិករ កាត់បន្ថយការខូចខាតនិងបាក់ច្រោះដីដែលបណ្តាលមកពីផលិតកម្មដំឡូងមីនិងដើម្បីជួយកសិករអោយទទួលយកនូវបច្ចេកទេសផលិតកម្មប្រកបដោយនិរន្តរភាពបរិស្ថាន។ គម្រោងនេះនឹងអនុវត្តទៅលើផ្នែកសំខាន់ៗពីរ គឺទីមួយផ្តោតការធ្វើពិសោធន៍លើបច្ចេកទេសដាំដំឡូងមី និងផ្នែកទីពីរគឺផ្តោតលើការប្រមូលទិន្នន័យពីការដាំដុះដំណាំដំឡូងមីនិងដំណាំកសិកម្មផ្សេងៗរបស់កសិករព្រមទាំងបញ្ហាជួបប្រទះផ្សេងៗនៅក្នុងភូមិចំនួន១៣ (សូមមើលបញ្ជីឈ្មោះភូមិភ្ជាប់ខាងក្រោម)។

## ការចាប់ផ្តើមគម្រោង

អង្គការដៃគូដើម្បីការអភិវឌ្ឍន៍ជនបទ (PRD)និងគម្រោង ACIAR ASEM/2013/003 បានរៀបចំការប្រជុំមួយស្តីពីការចាប់ផ្តើមគម្រោងស្រាវជ្រាវថ្មីកាលពីថ្ងៃទី០៤ ខែសីហាឆ្នាំ២០១៧ នៅសណ្ឋាគាម៉េម៉ូរីយ៉ាផាលេសនិងរីសតនៅក្រុងប៉ៃលិននិងការញ៉ាំអាហាររួមគ្នាជាមួយដៃគូពាក់ព័ន្ធ ជាពិសេសមានការអញ្ជើញចូលរួមជាភ្ញៀវកិត្តិយសពីសំណាក់ ឯកឧត្តម កើត សុធា អភិបាលនៃគណៈអភិបាលក្រុងប៉ៃលិន។

កិច្ចប្រជុំនេះមានគោលបំណងបង្កើតកិច្ចសហការនិងការគាំទ្រពីអាជ្ញាធរនិងដៃគូពាក់ព័ន្ធនានានៅក្នុងក្រុងប៉ៃលិននិងស្រុកសំឡូត ខេត្តបាត់ដំបង អំពីការដាក់បញ្ចូលបច្ចេកវិទ្យាកសិកម្មរបស់កសិករ នៅក្នុងខេត្តប៉ៃលិននិងបាត់ដំបង។ គម្រោងស្រាវជ្រាវនេះគឺផ្តោតសំខាន់ទៅលើការអនុវត្តរបស់កសិករ ដើម្បីវិភាគអំពីផលវិបាក និង

ឱកាស ដែលកសិករកំពុងប្រឈមនៅក្នុងតំបន់ ជាពិសេសការផ្លាស់ប្តូរការដាំដុះដំណាំដូចជាដំឡូងមី ដែលកំពុងរីកដុះដាលបានផ្តល់ជាករណីសម្រាប់វិភាគលើទស្សនៈវិស័យរបស់កសិករ និង ការសម្រេចចិត្តរបស់ពួកគេនៅក្នុងការធ្វើចម្ការ។ ក្នុងកំឡុងពេលប្រជុំ ក្រុមការងារក៏បានចុះទៅពិនិត្យចម្ការដំឡូងមីនិងជំងឺដំឡូងមីផ្សេងៗ។ ព័ត៌មានបន្ថែមអំពីគម្រោងអាចរកមើលបាននៅលើគេហទំព័រ https://farmerdecisionmaking.com/wp/







ក្រោយពីកិច្ចប្រជុំបានបញ្ចប់ អង្គការ PRD និងគម្រោងASEM/2013/003 បានចាប់ផ្តើមសកម្មភាពរបស់ខ្លួនបន្តបន្ទាប់ដូចខាងក្រោម។

## សកម្មភាពចុះប្រមូលទិន្នន័យពីការដាំដុះដំឡូងមី

ការប្រមូលទិន្នន័យបានចាប់ផ្តើមដោយធ្វើការចុះជួបជាមួយអាជ្ញាធរភូមិឃុំនៅក្នុងភូមិគោលដៅទាំងអស់ ដើម្បីប្រមូលស្ថិតិប្រជាពលរដ្ឋ ដែលមានដីសម្រាប់ដាំដុះដំណាំកសិកម្ម។ ក្រោយពីប្រមូលបានស្ថិតិទាំងនោះហើយ ការធ្វើសម្ភាសន៍បានចាប់ផ្តើមដោយជ្រើសរើសយកកសិករតែ៣០គ្រួសារក្នុងភូមិនីមួយៗ សរុបទាំងអស់១៣ភូមិ។ ការសម្ភាសន៍វគ្គទីមួយធ្វើឡើងពីខែធ្នូឆ្នាំ២០១៧ ដល់ខែឧសភាឆ្នាំ២០១៨។ វគ្គទីពីរនឹងចាប់ផ្តើមក្នុងខែសីហាឬកញ្ញាឆ្នាំ២០១៨ខាងមុខនេះ។







## សកម្មភាពពិសោធន៍លើបច្ចេកទេសដាំដំឡូងមី

អង្គការបានចាប់ផ្តើមធ្វើសកម្មភាពពិសោធន៍លើការដាំដុះដំណាំដំឡូងមីចំនួនពីរកន្លែង (មួយកន្លែងនៅភូមិពេជ្រគីរី ខេត្តប៉ៃលិន និង មួយកន្លែងទៀតនៅភូមិកំពង់ទូក ស្រុកសំឡូត ខេត្តបាត់ដំបង) ដែលកន្លែងនីមួយៗមានផ្ទៃដីទំហំ២ហិកតា។ ការពិសោធន៍គឺធ្វើទៅលើការដាំដុះដំឡូងមីលើថ្នាលពិសោធន៍ចំនួន៨ប្រភេទ ដែលរួមមាន ការដាំឆ្លាស់ជាមួយដំណាំផ្សេងៗ ការដាំដោយផ្តោតលើពេលវេលា ការដាំបញ្ឈរនិងផ្តេក និងចំនួនដើមដែលដាំក្នុង១ហិកតា/ប្លង់។ ការប្រមូលផលពីចម្ការពិសោធន៍ក្នុងឆ្នាំទីមួយ ធ្វើឡើងនៅខែមីនានិងខែមេសាឆ្នាំ២០១៨ ហើយទិន្នន័យនៃការប្រមូលផលនោះ កំពុងត្រូវបានធ្វើការវិភាគរកលទ្ធផលនៅឡើយ។

អង្គការដៃគូដើម្បីការអភិវឌ្ឍជនបទ Partners for Rural Development (PRD)
អាស័យដ្ឋាន៖ ផ្ទះលេខ ១៦៩, ក្រុមទី៨, ភូមិព្រែកតាតាន់ សង្កាត់ព្រែកព្រះស្តេច ក្រុង-ខេត្តបាត់ដំបង
Tel: (855) - 12 67 39 54 E-mail: sokuntheanuon@yahoo.com; manikayim@gmail.com

ការដាំដុះដំឡូងមីក្នុងចម្ការពិសោធន៍នៅឆ្នាំទីពីរ បានបញ្ចប់ទៅថ្មីៗនេះ។ ទោះជាយ៉ាងណា ការលូតលាស់របស់ដំណាំមានការយឺតយ៉ាវព្រោះមានភ្លៀងច្រើនពេក។ ដើមដំឡូងមួយចំនួនដាំមិនដុះដោយសារដើមដែលរក្សាទុកធ្វើពូជមានរយៈពេលយូររហូតដល់៣ខែទើបបានដាំ ដែលជាហេតុធ្វើអោយរលួយដើមឬស្អុយ។ ខណៈដែលជំងឺដំឡូងឈ្មោះម៉ូសាអិក (CMD) ត្រូវបានគេរកឃើញនៅទូទាំងតំបន់ក្នុងឆ្នាំនេះ ក៏វាមិនឃើញកើតមាននៅលើថ្នាលពិសោធន៍របស់យើងនៅក្នុងដំណាក់កាលនេះដែរ។










ជាផ្នែកមួយនៃគោលបំណងរបស់គម្រោង គឺការអនុវត្តប្តូរប្រព័ន្ធកសិកម្មពីការដាំដំណាំដំឡូងមីមួយហិកតាទៅជាប្រព័ន្ធកសិកម្មដែលកសិករចង់បាន។ តាមរយៈការសម្ភាសន៍ជាមួយកសិករភាគច្រើនបានបង្ហាញថាពួកគេចង់ប្តូរពីការដាំដំណាំដំឡូងមីទៅជាដំណាំឈើហូបផ្លែនៅលើចម្ការរបស់គេ។ ដូច្នេះហើយ ដីចម្ការពិសោធន៍មួយហិកតានៅក្នុងតំបន់ទាំងពីរ ត្រូវបានផ្តួចផ្តើមយកមកដាំដំណាំឈើហូបផ្លែដែលយើងគិតថាជាការអនុវត្តល្អនិងជាគំរូឬឧទាហរណ៍សម្រាប់កសិករ។

ចម្ការឈើហូបផ្លែមួយហិកតានៅតំបន់សំឡូតពេលនេះបានបំពាក់នូវប្រព័ន្ធស្រោចស្រពខ្នាតតូចនិងបានដាំដំណាំឈើហូបផ្លែមានដូចជាមង្ឃុត ស្វាយ តាង៉ែន និង ទុរេន។ ការផ្សាំពូជទុរេនតាមរបៀបផ្សេងៗត្រូវបានវាយតម្លៃទៅលើភាពធនទៅនឹងជំងឺរីស ព្រមទាំងគុណភាពនិងរសជាតិ (ពេលវាចាប់ផ្តើមចេញផ្លែ)។ ដូចគ្នានេះដែរ ដំណាំស្វាយក៏ត្រូវបានដាំនៅក្នុងចម្ការនេះ តាមរយៈការដាំដោយផ្សាំតាមពូជស្វាយប្រភេទខុសគ្នា ដើម្បីមើលទៅលើភាពធននៃដើមនិងគុណភាពផ្លែ ទល់នឹងស្វាយដែលដាំដោយបណ្តុះគ្រាប់ (អត់ផ្សាំ)។

ចំណែកឯចម្ការឈើហូបផ្លែមួយហិកតានៅតំបន់ប៉ៃលិនវិញ ត្រូវបានចាប់ផ្តើមដាំដំណាំស្វាយដោយផ្អែកលើទឹកភ្លៀង (មិនមានប្រពន្ធ័ស្រោចស្រព) ហើយនេះក៏ជាអ្វីដែលកសិករភាគច្រើនបានដាំនិងចង់ដាំ។ ជាថ្មីម្តងទៀតការដាំដុះនេះគឺ ផ្សាំពូជស្វាយតាមប្រភេទផ្សេងៗគ្នាពីប្រទេសថៃ ហើយយកមកប្រៀបធៀបលទ្ធផល ជាមួយស្វាយកែវរមៀតដែលដាំដោយបណ្តុះគ្រាប់(និងផ្សាំ)ជាលក្ខណៈស្តង់ដាររបស់ក្រុមហ៊ុននៅស្រុកខ្មែរ។ ការដាំឈើហូបផ្លែនៅចម្ការនេះ ក៏ផ្តោតលើចំនួនដើម ដែលត្រូវដាំក្នុងមួយហិកតាព្រមទាំងការប្រើប្រាស់ជីនៅលើថ្នាលនោះផងដែរ។

ចម្ការពិសោធន៍ឈើហូបផ្លែទាំងពីរកន្លែង ត្រូវបានដាំដំណាំឆ្លាស់នៅចន្លោះដើមឈើទាំងនោះ ធ្វើជាគម្របដីដើម្បីកាត់បន្ថយការហូរច្រោះដីដោយសារភ្លៀងនិងខ្យល់ខ្លាំង ការប្រើប្រាស់ទឹកអោយអស់លទ្ធភាព ព្រមទាំងទទួលបានប្រាក់ចំណូលពីដំណាំឆ្លាស់នោះផងដែរ។ ដំណាំឆ្លាស់ដែលដាំនៅចម្ការឈើហូបផ្លែនៅតំបន់សំឡូតមានដូច

ជាសណ្តែកបាយ សណ្តែកដី និងពោត រីឯនៅប៉ៃលិនវិញមានសណ្តែកដី សណ្តែកសៀង និងពោត។ គួរកត់សម្គាល់ផងដែរថា ពូជសណ្តែកបាយដែលយកមកដាំ ជាប្រភេទបង្កើនគ្រាប់ យកមកពីប្រទេសអូស្ត្រាលី ដែលផ្តល់ដោយគម្រោងបងប្អូនACIAR (CSE/2015/044) សម្រាប់ចែកចាយនៅក្នុងប្រទេសកម្ពុជា។ ពពួកពូជសណ្តែកបាយ ផ្តល់សក្តានុពលទិន្នផលល្អ ហើយកម្ពស់ផ្លែខ្ពស់ពីដីសមល្មមដែលអាចឱ្យការប្រមូលផលដោយម៉ាស៊ីនមានភាពងាយស្រួល។






## ការបណ្តុះបណ្តាល

ការបណ្តុះបណ្តាលដំបូងសម្រាប់គម្រោងផ្តោតទៅលើអង្គការដៃគូនៅក្នុងស្រុកនិងការទទួលខុសត្រូវរបស់គេដើម្បីរៀបចំអនុវត្តការចុះជួបសម្ភាសន៍តាមផ្ទះ។ ការបណ្តុះបណ្តាលនេះត្រូវបានធ្វើឡើងនៅក្នុងខែសីហា ឆ្នាំ២០១៧។ ហើយក្នុងឆ្នាំ២០១៨នេះ នឹងមានការបណ្តុះបណ្តាលមួយទៀតនៅក្នុងខែសីហានេះផងដែរ។ គម្រោងនេះក៏បានរួមចំណែកយ៉ាងសំខាន់ក្នុងការបង្កើនសមត្ថភាពបុគ្គលិក ដែលជាក់ស្តែងក្នុងឆ្នាំទីមួយនេះ លោក ផាន សុផាន់ណារ៉ា ជាប្រធានផ្នែកក្សេត្រសាស្ត្រនៃមន្ទីរកសិកម្មខេត្តប៉ៃលិន ទទួលបានអាហារូបករណ៍ផ្នែកអនុបណ្ឌិតពីសាកលវិទ្យាល័យបច្ចេកវិទ្យាស៊ូរ៉ាណារី (SUT) នៅខេត្តណាកនរ័ត្នឈិសេម៉ា ប្រទេសថៃ។ ការសិក្សារបស់គាត់ចាប់ផ្តើមនៅចុងខែកក្កដាឆ្នាំ២០១៨ ហើយផ្តែកទៅលើការស្រាវជ្រាវស្ទួលរបស់គម្រោងដែលជាគម្រោងស្រាវជ្រាវលើដំណាំដំឡូងមីនៅលើចម្ការពិសោធន៍ទាំងពីរកន្លែងនោះ។

## ផលប៉ះពាល់លើកសិករ

កសិករនៅក្នុងភូមិគោលដៅទាំង១៣ទទួលបានការណែនាំនិងពន្យល់អំពីសកម្មភាពគម្រោង តាមរយៈមេភូមិនិងការចុះសម្ភាសន៍តាមផ្ទះប្រហែលជា៣០គ្រួសារក្នុងមួយភូមិ។ សំនួរដែលត្រូវសួរសំខាន់ៗគឺចង់ដឹងថាតើកសិករមានចំណាប់អារម្មណ៍ចង់ទៅមើលកន្លែងធ្វើពិសោធន៍របស់អង្គការដែរឬទេ និង មួយផ្នែកទៀតក្រុមប្រមូលព័ត៌មានកំពុងដំណើរការពិភាក្សាពីភាពប្រសើរឡើងនូវទំនាក់ទំនងគ្នារវាងភូមិគោលដៅនិងចំការពិសោធន៍។ ក្នុងការបង្កើតទំនាក់ទំនងរវាងចម្ការពិសោធន៍និងភូមិគោលដៅវាមិនធ្វើអោយប៉ះពាល់ដល់ការចំណាយរបស់កសិករឡើយ។ ការផ្តួច ផ្តើមធ្វើបង្ហាញទាំងនេះជាជំហានមួយឆ្ពោះទៅរកការយល់ដឹងនិងបង្កើតទំនាក់ទំនងចាំបាច់ដើម្បីអោយយល់ពីដំណោះស្រាយរបស់កសិករនិងលទ្ធផលនៃការធ្វើការសម្រេចចិត្ត។

**<u>ឯកសារភ្ជាប់</u>**

១-បញ្ជីរឈ្មោះភូមិគោលដៅ
២-កាលវិភាគចុះសម្ភាសន៍

*អង្គការដៃគូដើម្បីការអភិវឌ្ឍជនបទ* **Partners for Rural Development (PRD)**
*អាស័យដ្ឋាន៖ ផ្ទះលេខ ១៦៩, ក្រុមទី៨, ភូមិព្រែកតាតាន់ សង្កាត់ព្រែកព្រះស្តេច ក្រុង-ខេត្តបាត់ដំបង*
Tel: (855) - 12 67 39 54 E-mail: sokuntheanuon@yahoo.com; manikayim@gmail.com

# បញ្ជីឈ្មោះភូមិគោលដៅ
# របស់អង្គការដៃគូដើម្បីការអភិវឌ្ឍជនបទ
-----------------

| លរ | ឈ្មោះភូមិ | ឈ្មោះឃុំ/ខណ្ឌ | ឈ្មោះស្រុក/ក្រុង | សកម្មភាពអនុវត្ត | លេខទំនាក់ទំនង |
|---|---|---|---|---|---|
| ប៉ៃលិន | | | | | |
| 1 | សួនអំពៅកើត | ប៉ៃលិន | ប៉ៃលិន | កសិកម្ម(ការពិសោធន៍និងប្រមូលទិន្នន័យលើដំណាំដំឡូងមី) | លោកមេភូមិ ជៀន ហៃ Mr. Chien Hai (097 766 9412) លោកអនុភូមិ អ៊ុច ស្រិត Mr. Uch Sreth (097 889 6655) |
| 2 | ទឹកផុស | ប៉ៃលិន | ប៉ៃលិន | ផ្នែកកសិកម្ម អប់រំទូទៅនិង សកម្មភាពផ្សេងៗរបស់អង្គការ | លោកមេភូមិ សាន សឿន Mr. San Soeurn (097 916 9357) |
| 3 | ពេជ្រ គីរី | ប៉ៃលិន | ប៉ៃលិន | ផ្នែកអប់រំទូទៅនិង សកម្មភាព ផ្សេងៗរបស់អង្គការ | លោកមេភូមិ ម៉ែន ទង Mr. Men Toung (097 526 5997) |
| 4 | ក្រចាប់ | អូតាវៅ | ប៉ៃលិន | កសិកម្ម(ការពិសោធន៍និងប្រមូលទិន្នន័យលើដំណាំដំឡូងមី) | លោកមេភូមិ អែម ហ៊ីម Mr. Em Him (097 619 2784) លោកអនុភូមិ ចក់ ហេង Mr. Chak Heng (097 669 7200) |
| 5 | អូរអិល | ស្ទឹងកាច់ | សាលាក្រៅ | កសិកម្ម(ការពិសោធន៍និងប្រមូលទិន្នន័យលើដំណាំដំឡូងមី) | លោកស្រីមេភូមិ គង់ ស្រី Mrs. Kong Srey |

| | | | | | |
|---|---|---|---|---|---|
| | | | | | (097 571 0551/ 016 588 489) លោកជំនួយការភូមិ មិត្ត ស៊ន Mr. Mith Sorn (092 976 692) |
| 6 | អណ្តូងថ្ម | ស្ទឹងកាច់ | សាលាក្រៅ | ផ្នែកអប់រំទូទៅនិងសកម្មភាព ផ្សេងៗទៀតរបស់អង្គការ | |
| 7 | អូរឫស្សីក្រោម | សាលាក្រៅ | សាលាក្រៅ | កសិកម្ម(ការពិសោធន៍និងប្រមូលទិន្នន័យលើដំណាំ ដំឡូងមី) | លោកមេភូមិ អ៊ុក ស្រេង Mr. Ouk Sreng (069 876 316) |
| 8 | សួនអំពៅលិច | ប៉ៃលិន | ប៉ៃលិន | កសិកម្ម(ការពិសោធន៍និងប្រមូលទិន្នន័យលើដំណាំ ដំឡូងមី) | លោកមេភូមិ នេត ទី Mr. Net Ty (088 3077 989) |
| 9 | តាង៉ែនលើ | ប៉ៃលិន | ប៉ៃលិន | កសិកម្ម(ការពិសោធន៍និងប្រមូលទិន្នន័យលើដំណាំ ដំឡូងមី) | លោកមេភូមិ យ៉ាំង ឌី Mr. Yang Dy (097 766 9411) |
| | | | សំឡូត | | |
| 1 | ដូនត្រឹក | តាសាញ | សំឡូត | ផ្នែកកសិកម្ម អប់រំទូទៅនិងសកម្មភាពផ្សេងៗទៀតរបស់អង្គការ | លោកស្រីមេភូមិ ប្រាក់ ឃឿន (097 453 0571) |
| 2 | អូរស្ងួត | តាសាញ | សំឡូត | ផ្នែកកសិកម្ម អប់រំទូទៅនិង សកម្មភាព ផ្សេងៗទៀតរបស់អង្គការ | លោកមេភូមិ តឹក ថន Mr. Toek Thorn (097 779 6976, 093/012 796976) លោកស្រីអនុភូមិ ជួន សុខា Mrs. Chuon Sokha (071 852 5280) |
| 3 | កំពង់ទូក | មានជ័យ | សំឡូត | កសិកម្ម(ការពិសោធន៍និងប្រមូលទិន្នន័យលើដំណាំដំឡូងមី) | លោកមេភូមិ នូ វណ្ណៈ Mr. Nou Vannak (097 263 3613) |

| | | | | | |
|---|---|---|---|---|---|
| 4 | ព្រៃរំចេក | តាសាញ | សំឡូត | ផ្នែកអប់រំទូទៅនិង សកម្មភាព ផ្សេងៗទៀតរបស់ អង្គការ | |
| 5 | កំចាត់ | មានជ័យ | សំឡូត | ផ្នែកអប់រំទូទៅនិង សកម្មភាព ផ្សេងៗទៀតរបស់ អង្គការ | |
| 6 | ចម្លងរមាំងលើ | អូរសំរិល | សំឡូត | ផ្នែកអប់រំទូទៅនិង សកម្មភាព ផ្សេងៗទៀតរបស់ អង្គការ | |
| 7 | តានន | មានជ័យ | សំឡូត | កសិកម្ម(ការពិសោធន៍ និងប្រមូលទិន្នន័យលើ ដំណាំដំឡូងមី) | លោកមេភូមិ កែវ រិទ្ធី Mr. Keo Rithy (069 242 771) - |
| 8 | អំពិប | មានជ័យ | សំឡូត | កសិកម្ម(ការពិសោធន៍ និងប្រមូលទិន្នន័យលើ ដំណាំដំឡូងមី) | លោកមេភូមិ កែ នីម Ke Nim 0975478811 |
| 9 | ស្រែជីពៅ | មានជ័យ | សំឡូត | កសិកម្ម(ការពិសោធន៍ និងប្រមូលទិន្នន័យលើ ដំណាំដំឡូងមី) | លោកមេភូមិ ទង់ រិន Mr. Tung Rin (092 37 64 27) |

# កាលវិភាគចុះស្រង់ព័ត៌មាន
# នៅក្នុងខេត្តប៉ៃលិន និង សំឡូត

| ថ្ងៃខែឆ្នាំ<br>Date | សកម្មភាព<br>Activities | ភូមិ<br>Village | ឃុំ/សង្កាត់<br>Commune | ខេត្ត/ក្រុង<br>Province | អ្នកទទួលខុសត្រូវ<br>Responsible person |
|---|---|---|---|---|---|
| ៤-៨/១២/១៧ | ចុះធ្វើសម្ភាសន៍ | កំពង់ទូក | មានជ័យ | បាត់ដំបង | គន្ធានិងម៉ានីកា |
| ១៨-២២/១២/១៧ | ចុះធ្វើសម្ភាសន៍ | សួនអំពៅកើត | ប៉ៃលិន | ប៉ៃលិន | គន្ធានិងម៉ានីកា |
| ២-៥/០១/១៨ | ចុះធ្វើសម្ភាសន៍ | តានន | មានជ័យ | បាត់ដំបង | គន្ធានិងម៉ានីកា |
| ១៥-១៩/០១/១៨ | ចុះធ្វើសម្ភាសន៍ | តាង៉ែនលើ | ប៉ៃលិន | ប៉ៃលិន | គន្ធានិងម៉ានីកា |
| ៥-៩/០២/១៨ | ចុះធ្វើសម្ភាសន៍ | អំពិប | មានជ័យ | បាត់ដំបង | គន្ធានិងម៉ានីកា |
| ១៩-២៣/០២/១៨ | ចុះធ្វើសម្ភាសន៍ | សួនអំពៅលិច | ប៉ៃលិន | ប៉ៃលិន | គន្ធានិងម៉ានីកា |
| ៥-៩/០៣/១៨ | ចុះធ្វើសម្ភាសន៍ | ស្រែជីពៅ | មានជ័យ | បាត់ដំបង | គន្ធានិងម៉ានីកា |
| ១៩-២៣/០៣/១៨ | ចុះធ្វើសម្ភាសន៍ | ទឹកផុស | សាលាក្រៅ | ប៉ៃលិន | គន្ធានិងម៉ានីកា |
| ២-៦/០៤/១៨ | ចុះធ្វើសម្ភាសន៍ | អូរស្នួត | តាសាញ | បាត់ដំបង | គន្ធានិងម៉ានីកា |
| ២៣-២៧/០៤/១៨ | ចុះធ្វើសម្ភាសន៍ | អូររអិល | ស្ទឹងកាច់ | ប៉ៃលិន | គន្ធានិងម៉ានីកា |
| ៧-១១/០៥/១៨ | ចុះធ្វើសម្ភាសន៍ | ដូនត្រិត | តាសាញ | បាត់ដំបង | គន្ធានិងម៉ានីកា |
| ២២-២៥/០៥/១៨ | ចុះធ្វើសម្ភាសន៍ | ក្រចាប់ | អូរតាវៅ | ប៉ៃលិន | គន្ធានិងម៉ានីកា |
| ៤-៨/០៦/១៨ | ចុះធ្វើសម្ភាសន៍ | អូរឬស្សីក្រោម | ប៉ៃលិន | ប៉ៃលិន | គន្ធានិងម៉ានីកា |

*អង្គការដៃគូដើម្បីការអភិវឌ្ឍជនបទ* **Partners for Rural Development (PRD)**
*អាស័យដ្ឋាន៖ ផ្ទះលេខ ១៦៩, ក្រុមទី៨, ភូមិព្រែកតាតាន់ សង្កាត់ព្រែកព្រះស្ដេច ក្រុង-ខេត្តបាត់ដំបង*
Tel: (855) - 12 67 39 54 E-mail: sokuntheanuon@yahoo.com; manikayim@gmail.com